**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

លេខ ០០៤ .....

រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០៧

# សារាចរណែនាំ

## ស្តីពី

## ការគ្រប់គ្រងមធ្យោបាយធ្វើអាជីវកម្ម ដឹកជញ្ជូនទេសចរធ្វើដំណើរទស្សនាកំសាន្តតាមផ្លូវគោក

ដើម្បីគ្រប់គ្រងការធ្វើអាជីវកម្មមធ្យោបាយដឹកជញ្ជូនទេសចរ ធ្វើដំណើរទស្សនាកំសាន្តតាមផ្លូវគោក អោយមានសណ្តាប់ធ្នាប់ របៀបរៀបរយ ប្រកបដោយសន្តិសុខ សុវត្ថិភាព មានសុជីវធម៌ជូនទេសចរជាតិ-អន្តរជាតិ និង ក្នុងគោលបំណងធានាការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ថែរក្សាការពារវប្បធម៌ ប្រពៃណីជាតិ តាមគោលនយោបាយអភិវឌ្ឍន៍វិស័យទេសចរណ៍របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងដើម្បីអនុវត្តប្រកាសលេខ ០៦៤ ប្រ.ក ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ក្រសួងទេសចរណ៍សូមធ្វើការណែនាំដូចខាងក្រោម:

១: - រាល់ការធ្វើអាជីវកម្មដឹកជញ្ជូនទេសចរធ្វើដំណើរកំសាន្តតាមផ្លូវគោក អាជីវករត្រូវមានអាជ្ញាប័ណ្ណទេសចរណ៍ ពីក្រសួង ឬមន្ទីរទេសចរណ៍ខេត្ត-ក្រុង ។ ទំរង់បែបបទនៃការសុំធ្វើអាជីវកម្ម ត្រូវបានបំពេញឡើងដោយម្ចាស់ ឬ អ្នកគ្រប់គ្រងយានយន្ត និងត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងទេសចរណ៍ ។

- ឯកសារផ្សេងៗទៀត ដែលក្រសួងទេសចរណ៍ត្រូវការ រួមមាន :

  - កិច្ចសន្យារបស់ម្ចាស់អាជីវកម្មចំពោះក្រសួងទេសចរណ៍ ក្នុងការប្រកបអាជីវកម្ម
  - កិច្ចសន្យាជំពាក់ឯកសារ ដែលត្រូវបំពេញឡើងវិញក្នុងរយៈពេល ០៣ខែ
  - ត្រូវបំពេញតារាងត្រួតពិនិត្យយានយន្ត

២: ក្នុងការធ្វើអាជីវកម្ម អាជីវករត្រូវគោរពអនុវត្តតាមសារាចរណែនាំ និង បទប្បញ្ញត្តិ ស្តីអំពីការធ្វើអាជីវកម្ម ដឹកជញ្ជូនទេសចរទស្សនាកំសាន្តតាមផ្លូវគោក ច្បាប់ការងារ ព្រមទាំងច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀតរបស់រដ្ឋ ដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មទេសចរណ៍ ដើម្បីជាកិច្ចធានាដល់សន្តិសុខ សុវត្ថិភាព សុខុមាលភាពជូនទេសចរ ។

៣: រាល់ការធ្វើអាជីវកម្មដឹកជញ្ជូនទេសចរ ត្រូវធានាថាមិនធ្វើអោយប៉ះពាល់ដល់វប្បធម៌ ប្រពៃណីជាតិ សណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន និង របៀបរៀបរយសង្គម។

# ៣ មហាវិថីព្រះមុនីវង្ស ភ្នំពេញ ១២២៥៨ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥) ២៣ ២១៣ ៧៤១ ទូរសារ: (៨៥៥) ២៣ ២២០ ៧០៤, អ៊ីមែល: info@mot.gov.kh Website: www.mot.gov.kh

ត្រូវផ្តល់ដំណឹងជាលាយល័ក្ខអក្សរជូនក្រសួងទេសចរណ៍ពេលមានការបិទអាជីវកម្ម ផ្លាស់ប្តូរឈ្មោះម្ចាស់ ឬអ្នកគ្រប់គ្រង អាជីវកម្ម លេខទូរស័ព្ទ ទូរសារ ព្រមទាំងពត៌មានអំពីចំនួនអ្នកដំណើរ ថ្លៃឈ្នួល ដែលក្រសួង ឬមន្ទីរទេសចរណ៍ត្រូវការ ។ ដើម្បីពង្រឹងនូវលក្ខណ:សម្បត្តិ គុណភាពសេវាកម្ម អាជីវករត្រូវអនុវត្តតាមបទដ្ឋានបច្ចេកទេស និងស្តង់ដាដូច ខាងក្រោម:

- កៅអីពូក ត្រូវធានាគុណភាព ស្អាត និងមានបង់លេខសំគាល់ ។
- មិនអនុញ្ញាតអោយដឹកជញ្ជូនអ្នកទេសចរ លើសពីចំនួនកៅអីដែលបានកំណត់ ។
- ចំពោះយានយន្ត ដែលមានចំណុះចាប់ពី ១៨ កៅអីឡើងទៅ ត្រូវបំពាក់ឧគ្ឃោសនស័ព្ទ ដើម្បីឧទ្ទេសនាម ជូនទេសចរ ។
- សំបុត្រជិះយានយន្តត្រូវមានដាក់ថ្លៃ លេខកៅអី និងពេលវេលាចេញដំណើរច្បាស់លាស់ ។
- ក្នុងយានយន្ត ត្រូវមានបទបញ្ជា ឬការណែនាំអំពីអនាម័យ ថែទាំបរិស្ថាន សុវត្ថិភាព និងវិធីបង្ការគ្រោះថ្នាក់ ផ្សេងៗដែលអាចកើតមានឡើងដោយចៃដន្យ។ បន្ទប់ទឹកក្នុងយានយន្ត ត្រូវស្អាត និងមានអនាម័យគ្រប់គ្រាន់ ។
- យានយន្ត ត្រូវបំពាក់គ្រឿងឧបករណ៍ពន្លត់អគ្គីភ័យ និងមានវិទ្យុទាក់ទង ( ICOM ) ឬទូរស័ព្ទប្រចាំការ ដើម្បី បង្ការពេលមានគ្រោះថ្នាក់កើតឡើង ព្រមទាំងត្រូវមានប្រអប់ថ្នាំសង្គ្រោះបន្ទាន់សំរាប់តំរូវការប្រើប្រាស់ នៅពេល ចាំបាច់ ។
- យានយន្ត ត្រូវមានកន្លែងទុកដាក់ឥវ៉ាន់ភ្ញៀវអោយបានសមរម្យ មិនត្រូវផ្ទុកឥវ៉ាន់ក្រៅពីឥវ៉ាន់អ្នកដំណើរ និង លើសចំណុះផ្ទុករបស់យានយន្ត ។
- ហាមមានអាវុធជាតិផ្ទុះនៅលើយានយន្ត ។
- អាជ្ញាប័ណ្ណទេសចរណ៍ និងវិញ្ញាបនប័ត្របច្ចេកទេសយានយន្ត ត្រូវថែរក្សាអោយបានល្អ និងដាក់ជាប់តាម យានយន្ត ។
- អ្នកបើកបរមិនត្រូវមានសារធាតុញៀន ឬស្រវឹងក្នុងខ្លួន ។
- អ្នកបើកបរ និងបុគ្គលិកបំរើលើយានយន្ត ត្រូវស្លៀកពាក់ឯកសណ្ឋាន មានផ្លាកឈ្មោះសំគាល់ មានអាកប្បកិរិយា ថ្លៃថ្នូរ សុជីវធម៌ និងគោរពសិទ្ធិ ផលប្រយោជន៍របស់ភ្ញៀវ ។
- អ្នកបើកបរ និងបុគ្គលិកបំរើលើយានយន្តទាំងអស់ ត្រូវមានលិខិតបញ្ជាក់សុខភាព ដែលចេញដោយនាយកដ្ឋាន ពេទ្យការងារ ឬមន្ទីរសុខាភិបាលខេត្ត-ក្រុង ។
- ដើម្បីជៀសវាងការរំខានដល់ភ្ញៀវ ការចាក់កាសែតម៉ាញ៉េ កាសែតវីដេអូ ស៊ីឌី វីស៊ីឌី ឬ ឌីវីឌី ត្រូវរក្សា សំលេងមធ្យម ឬបំពាក់ឧបករណ៍ ( កាស ) ស្តាប់សំលេងដោយផ្ទាល់ ។ ហាមចាក់កាសែតវីដេអូ ស៊ីឌី វីស៊ីឌី ឬឌីវីឌី ដែលរដ្ឋហាមឃាត់ ។

រាល់សកម្មភាពធ្វើអាជីវកម្ម ជួញដូរគ្រឿងញៀន ត្រូវហាមឃាត់ ។

ត្រូវរាយការណ៍ជូនភ្នាក់ងារមានសមត្ថកិច្ចជាបន្ទាន់ នូវរាល់បាតុភាពអសកម្ម ដែលអាចកើតមានឡើង ឬនៅពេលមាន គ្រោះថ្នាក់ចរាចរ ដែលធ្វើអោយប៉ះពាល់ដល់សុវត្ថិភាពទេសចរ ។

ម្ចាស់អាជីវកម្ម អ្នកបើកបរត្រូវទទួលខុសត្រូវការពារ សន្តិសុខ សុវត្ថិភាព បរិស្ថាន អនាម័យ នៅលើយានយន្តអោយ បានល្អជានិច្ច ។

៩: ក្នុងករណីមិនគោរពតាមបទប្បញ្ញត្តិ ស្តីអំពីការធ្វើអាជីវកម្មដឹកជញ្ជូនទេសចរតាមផ្លូវគោក អាជីវករត្រូវទទួលនូវការផាកពិន័យ ឬទទួលទោសតាមច្បាប់រដ្ឋកំណត់ ។ ករណីធ្វើអោយប៉ះពាល់ធ្ងន់ធ្ងរ ដល់សុវត្ថិភាពភ្ញៀវ ឬបង្កអោយមានគ្រោះថ្នាក់ដល់ទេសចរ ត្រូវទទួលទោសតាមច្បាប់រដ្ឋជាធរមាន ។

១០: ម្ចាស់យានយន្តផ្ទាល់ខ្លួន ដែលបំរើសេវាកម្មទេសចរណ៍ ត្រូវមកបំពេញបែបបទដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីប្រកបអាជីវកម្មដឹកជញ្ជូនទេសចរតាមផ្លូវគោក ដែលត្រូវត្រួតពិនិត្យ និងអនុញ្ញាតដោយមន្ទីរទេសចរណ៍ ខេត្ត-ក្រុង ។

១១: ម្ចាស់យានយន្តរបស់ក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ និង របស់ក្រុមហ៊ុនដឹកជញ្ជូនទេសចរណ៍ ត្រូវមកបំពេញបែបបទដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ ដើម្បីប្រកបអាជីវកម្មដឹកជញ្ជូនទេសចរតាមផ្លូវគោក ដែលត្រូវត្រួតពិនិត្យ និងអនុញ្ញាតដោយក្រសួងទេសចរណ៍ ។

១២ : ក្នុងករណីចាំបាច់ ក្រសួងនឹងមានវិធានការចាត់តាំងអធិការ និង មន្ត្រីជំនាញ ចុះធ្វើអធិការកិច្ចលើការអនុវត្តន៍លិខិតបទដ្ឋានស្តីពីអាជីវកម្មដឹកជញ្ជូនទេសចរតាមផ្លូវគោករបស់ក្រសួង ។

១៣ : មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធត្រួតពិនិត្យលើអាជីវកម្មដែលប្រព្រឹត្តិផ្ទុយនឹងបទប្បញ្ញត្តិ របស់ក្រសួងទេសចរណ៍ និងរបស់រដ្ឋ និងរាយការណ៍មកក្រសួងទេសចរណ៍ ។

១៤: មន្ទីរទេសចរណ៍ ខេត្ត-ក្រុងត្រូវអនុវត្តអោយបានម៉ឺងម៉ាត់តាមគោលការណ៍កំណត់របស់ក្រសួងទេសចរណ៍ ។

ទទួលបាននូវសារាចរណែនាំនេះ មន្ទីរទេសចរណ៍ខេត្ត-ក្រុង ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីចាត់តាំងផ្សព្វផ្សាយដល់ម្ចាស់អាជីវកម្មដឹកជញ្ជូនទេសចរតាមផ្លូវគោក ដើម្បីអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ ។

រដ្ឋមន្ត្រី

ថោង ខុន

កន្លែងទទួល
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
  "ដើម្បីជូនជ្រាប"
- មន្ទីរទេសចរណ៍ខេត្ត-ក្រុង "ដើម្បីមុខការ"
- គ្រប់សហគ្រាសធ្វើអាជីវកម្មដឹកជញ្ជូនទេសចរធ្វើដំណើរកំសាន្តតាមផ្លូវគោក ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ